# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ, ថ្ងៃទី...០៤.... ខែ..កុម្ភៈ.... ឆ្នាំ.២០០៥....

លេខ..០១/២០០៥ កបធ..សជណ

**សូមទូលថ្វាយ**

**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា**

**កម្មវត្ថុ** : សំណើបកស្រាយមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**យោង** : - ព្រះរាជចំណារលេខ ០០៥ រស ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៥ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

- យោងលិខិតចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ របស់លោក **ម៉ុល នាង**

តបតាមព្រះរាជចំណារដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ទូលបង្គំសូមទូលថ្វាយដូចតទៅ :

សម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៥ បានទទួលព្រះរាជចំណារខាងលើមកពិនិត្យ ហើយយល់ឃើញថា :

១/-មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញទាក់ទងនឹងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញផង និងសមត្ថកិច្ចរបស់តុលាការផង :

ក- សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលពាក់ព័ន្ធនោះ មានជាអាទិ៍គឺ :បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ហើយនិងត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ( មាត្រា ១៣៦ ថ្មី និងមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញ ) ។

ខ- សមត្ថកិច្ចរបស់តុលាការ គ្រប់ថ្នាក់ និង គ្រប់ផ្នែក គឺជំនុំជម្រះក្តី (វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃមាត្រា ១២៨ ថ្មីនៃរដ្ឋធម្មនុញ្ញ ) ។

-តុលាការត្រូវពិនិត្យមើលពាក្យបណ្តឹងរបស់បុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ថាតើពាក្យបណ្តឹងនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់អំណាចតុលាការ ឬរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយមានជូនភស្តុតាងបញ្ជាក់គ្រប់គ្រាន់ទេ ។ បើបណ្តឹងនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចបានបញ្ជាក់ខាងលើ តុលាការសាមីត្រូវលើកករណីនេះជូនទៅតុលាការកំពូលក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរ ។ តុលាការកំពូលត្រូវចាត់ការពិនិត្យ និងប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១៥ ថ្ងៃ យ៉ាងយូរ លើកលែងតែតុលាការកំពូលយល់ឃើញថា ពាក្យបណ្តឹងតវ៉ានេះមិនអាចទទួលបាន ។

ផ្ទុយទៅវិញ បើតុលាការថ្នាក់ក្រោមពិនិត្យឃើញថា បណ្តឹងនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឬគ្មានមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់ទេនោះ តុលាការត្រូវចាត់ការតាមនីតិវិធីជាធរមាននៃអំណាចតុលាការ ហើយជូនដំណឹងអំពីការសម្រេចរបស់ខ្លួនដល់ម្ចាស់បណ្តឹង ។ ម្ចាស់បណ្តឹងមានសិទ្ធិប្តឹងតទៅទៀតតាមនីតិវិធីជាធរមាននៃអំណាចតុលាការ ។

២/-ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចធ្វើបទឧទ្ទេសនាមអំពីអ្វីដែលលោក ម៉ុល នាង បានលើកឡើងក្នុងឧទាហរណ៍របស់លោកនោះទេ ។

សូមសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាទ្រង់ព្រះមេត្តាជ្រាបនិងទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំ ។

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣, E-mail: sgcc@camnet.com.kh